# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតចំហ
## សូមគោរពជូន
## ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

**កម្មវត្ថុ** ៖ អង្គការសង្គមស៊ីវិលស្នើ **ឯកឧត្តម** បំភ្លឺអំពីការនាំខ្សាច់ចេញ ។

យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមស្នើឯកឧត្តមមេត្តាចេញសេចក្តីស្រាយបំភ្លឺអំពីការនាំខ្សាច់ពីប្រទេសកម្ពុជាទៅកាន់ប្រទេសនានា ក្នុងអំឡុងឆ្នាំ ២០០៧ ដល់ ឆ្នាំ២០១៥។ ឯកឧត្តម ឌិត ទីណា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងរ៉ែ និងថាមពល ត្រូវបានស្រង់សម្តី[1] ដែលបានមានប្រសាសន៍ថា បរិមាណខ្សាច់ដែលកម្ពុជានាំចេញជាសកលមានចំនួន ១០.៦៦៩.២១២ ម៉ែត្រគូប[2] ឬស្មើនឹង (ជាង១៧លានតោន) ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៥។ ប៉ុន្តែទិន្នន័យពាក់ព័ន្ធនឹងការនាំខ្សាច់ចេញទៅក្រៅប្រទេសជាផ្លូវការដែលរដ្ឋាភិបាលបានចេញមកទល់ពេលនេះមានប្រភពមកពីក្រសួងពាណិជ្ជកម្មប៉ុណ្ណោះ ដែលបង្ហាញត្រឹមតែការនាំខ្សាច់ចេញទៅកាន់ប្រទេសសិង្ហបុរីក្នុងអំឡុងពេលដូចគ្នានេះគឺមានប្រមាណតែ ២,៨ លានតោន។ ប៉ុន្តែរដ្ឋាភិបាលពុំទាន់បានពន្យល់ថាតើប្រទេសណាខ្លះទៀតដែលកម្ពុជាបាននាំខ្សាច់ទៅ ឬ ថាតើខ្សាច់ដែលនាំចេញទៅនោះលក់ក្នុងតម្លៃប៉ុន្មាននោះទេ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមស្នើឯកឧត្តមមេត្តាស្រាយបំភ្លឺនូវសំណួរដូចតទៅនេះ ៖ តើក្រសួងរ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ឬអគ្គនាយកដ្ឋានគយនិងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអាចបង្ហាញទិន្នន័យអំពីប្រទេសណាខ្លះដែលកម្ពុជាបាននាំខ្សាច់ចេញទៅចំនួនប្រមាណ១៧ លានតោន ក្នុងនោះរួមទាំងតម្លៃនៃការនាំខ្សាច់ចេញទៅប្រទេសនីមួយៗ និងក្នុងមួយឆ្នាំៗ? ទីពីរ តើក្រសួងណាមួយអាចបង្ហាញតួលេខនៃការនាំខ្សាច់ចេញទៅក្រៅប្រទេសសរុប តើមានប៉ុន្មានភាគរយនៃខ្សាច់យកមកពីប្រភពទឹកសាប (ដូចជា ប្រឡាយ ទន្លេ បឹង ជាដើម) ហើយប៉ុន្មានភាគរយយកមកពីសមុទ្រ[3] (ឧទាហរណ៍ ពីដែសមុទ្រ ជាដើម)?

---

[1] វិទ្យុអាស៊ីសេរី ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ តាមរយៈ http://bit.ly/2epNEQr និង វិទ្យុបារាំងអន្តរជាតិ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៦ តាមរយៈ http://rfi.my/2f2G5RU។

[2] តួលេខសរុបនៃការនាំខ្សាច់ចេញពីប្រទេសកម្ពុជាទៅបណ្តាប្រទេសផ្សេង២ទៀតចាប់តាំងពីឆ្នាំ២០០៧។

[3] ដែសមុទ្រនៅតាមណ្តោយឆ្នេរនៃខេត្តកោះកុង ដែលត្រូវបានរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានចាត់ទុកថាជា «ទឹកសមុទ្រ» ពីព្រោះមានបរិមាណទឹកប្រៃច្រើនជាងទឹកសាប។

យោងតាមទិន្នន័យពីក្រសួងពាណិជ្ជកម្ម កម្ពុជាបាននាំខ្សាច់ចេញក្នុងបរិមាណសរុបចំនួនប្រមាណ ២,៨ លានតោន ក្នុងតម្លៃ ៥,៥ លានដុល្លាសហរដ្ឋអាមេរិក ទៅកាន់ប្រទេសសិង្ហបុរីនៅចន្លោះឆ្នាំ២០០៧ និង ឆ្នាំ២០១៥។ ប៉ុន្តែយោងតាមប្រព័ន្ធទិន្នន័យស្ថិតិពាណិជ្ជកម្មលើទំនិញរបស់អង្គការសហប្រជាជាតិ [4] ដែលបង្ហាញទិន្នន័យរបស់នាយកដ្ឋានស្ថិតិពាណិជ្ជកម្មរបស់រដ្ឋាភិបាលសិង្ហបុរី[5]បង្ហាញតួលេខ ៧២,៨ លានតោននៃការនាំខ្សាច់ពីប្រទេសកម្ពុជាចូលមកសិង្ហបុរី។ ដូច្នេះហើយ តើក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ឬអគ្គនាយកដ្ឋានគយនិងរដ្ឋាករនៃក្រសួងហិរញ្ញវត្ថុ អាចធ្វើការពន្យល់អំពីមូលហេតុដែលនាំឱ្យមានគម្លាតគ្នាដល់ទៅបរិមាណខ្សាច់ចំនួន ជាង ៦៩,៩ លានតោន ក្នុងតម្លៃ ៧៤៦,៥ លានដុល្លាសហរដ្ឋអាមេរិក រវាងបរិមាណខ្សាច់ដែលរដ្ឋាភិបាលរាយការណ៍ថាបាននាំចេញទៅកាន់ប្រទេសសិង្ហបុរី និងបរិមាណខ្សាច់ដែលរដ្ឋាភិបាលសិង្ហបុរីរាយការណ៍ថាបាននាំមកពីប្រទេសកម្ពុជា?

យោងតាមលិខិតចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦[6] ឯកឧត្តមបានថ្លែងស្វាគមន៍ចំពោះសំណើនានារបស់សាធារណជនដែលមានបំណងចង់បានឯកសារពាក់ព័ន្ធនឹងការបូមខ្សាច់ក្នុងខេត្តកោះកុងដូចជា របាយ-ការណ៍អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងរបាយការណ៍អំពីទំនប់វារីអគ្គិសនីជាដើម។ យើងខ្ញុំសូមកោតសរសើរដល់ការប្តេជ្ញាចិត្តរបស់ឯកឧត្តមចំពោះការបង្ហាញនូវតម្លាភាពនេះ ហើយសូមឯកឧត្តមមេត្តាផ្តល់ព័ត៌មានតាមការប្តេជ្ញានេះតាមរយៈការផ្តល់ព័ត៌មានឱ្យបានពេញលេញតាមការស្នើសុំរបស់យើងខ្ញុំក្នុងលិខិតនេះ។ ម្យ៉ាងទៀត និយាយជាទូទៅ យើងខ្ញុំសូមស្នើឯកឧត្តម ចេញផ្សាយរបាយការណ៍អំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងទំនប់វារីអគ្គិសនីទាក់ទិនទៅនឹងការបូមខ្សាច់ជាសាធារណៈឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដើម្បីសាធារណជន សហគមន៍ដែលរងផលប៉ះពាល់និងសង្គមស៊ីវិលអាចស្វែងរកបាន។ ជាពិសេស យើងខ្ញុំសូមស្នើក្រសួងរ៉ែ និងថាមពល មេត្តាដាក់ឯកសារទាំងនេះនៅលើគេហទំព័ររបស់ក្រសួងផ្ទាល់តែម្តង ឬបើពុំដូច្នេះទេ សូមក្រសួងបំលែងរបាយការណ៍ទាំងនេះឱ្យទៅជាទិន្នន័យតាមបែបអេឡិចត្រូនិច ហើយផ្ញើទៅអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោមដោយអនុគ្រោះ។ យើងខ្ញុំជឿជាក់ថា ការធ្វើបែបនេះនឹងបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះការអភិវឌ្ឍដោយចីរភាព និងមានការចូលរួមគ្រប់ជ្រុងជ្រោយ ដូចមានគូសបញ្ជាក់នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពឆ្នាំ២០៣០។

---

[4] ប្រព័ន្ធទិន្នន័យស្ថិតិពាណិជ្ជកម្មលើទំនិញរបស់អង្គការសហប្រជាជាតិ អាចរកបានតាមរយៈ http://comtrade.un.org/data/។

[5] ទិន្នន័យរបស់នាយកដ្ឋានស្ថិតិពាណិជ្ជកម្មរបស់រដ្ឋាភិបាលសិង្ហបុរី អាចរកបានតាមរយៈ http://bit.ly/2dH7Eiz។

[6] លិខិតរបស់ក្រសួងរ៉ែ និងថាមពល ឯកឧត្តម ស៊ុយ សែម លេខ០៩៤៩ រចអធរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦។

ការបូមខ្សាច់ បើទោះជាធ្វើឡើងក្នុងចេតនាល្អក្តី ក៏អាចមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសហគមន៍មូលដ្ឋាន និងបរិស្ថានធម្មជាតិដែរ។[7] យើងខ្ញុំមានការព្រួយបារម្ភជាខ្លាំងថា របបចិញ្ចឹមជីវិត និងសិទ្ធិមនុស្សរបស់សហគមន៍ដែលរងការប៉ះពាល់បន្តរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារការបូមខ្សាច់នៅក្នុងប្រទេសកម្ពុជា។ជាងនេះទៀត យើងខ្ញុំបារម្ភអំពីផលប៉ះពាល់រយៈពេលវែងនៃការបូមខ្សាច់ទៅលើបរិស្ថានធម្មជាតិរបស់ប្រទេសកម្ពុជា។ យើងខ្ញុំកត់សម្គាល់ថា ការសម្រេចរបស់រដ្ឋាភិបាលប្រទេសវៀតណាម ឥណ្ឌូនេស៊ី និងម៉ាឡេស៊ីក្នុងការហាមប្រាម ឬ រឹតបន្តឹងការនាំខ្សាច់ចេញទៅប្រទេសសិង្ហបុរី គឺដោយសារតែការបារម្ភពីបរិស្ថាន ដូច្នេះហើយ យើងខ្ញុំសូមស្នើឯកឧត្តមពិចារណាដាក់ចេញបម្រាម ឬការរឹតបន្តឹងស្រដៀងគ្នានេះនៅក្នុងប្រទេសកម្ពុជា ដើម្បីផលប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់រយៈពេលវែងរបស់ប្រទេសកម្ពុជា។

យើងខ្ញុំ នៅតែប្រកាន់ជំហ និងមានឆន្ទៈសហការជាមួយរដ្ឋាភិបាលក្នុងដំណើរការអភិរក្សធនធានធម្មជាតិរបស់ប្រទេសកម្ពុជាឱ្យរីកចម្រើនបន្តទៀត និងក្នុងការបន្តដំណើរឆ្ពោះទៅការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តម ជាអនេកប្បការចំពោះការពិចារណាលើសំណើរបស់យើងខ្ញុំ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានដោយស្មោះស្ម័គ្រអំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦

*អង្គការសង្គមស៊ីវិលដែលគាំទ្រលិខិតចំហនេះ រួមមាន៖*

| ល.រ | នាមអង្គការសង្គមស៊ីវិល | នាមអ្នកចូលរួម | លេខទំនាក់ទំនង |
|---|---|---|---|
| *១* | *សម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA)* | *លោក សន ជ័យ* | *០១២ ៨៤៥ ៦៤២* |
| *២* | *សហគមន៍បឹងឈូក (ភ្នំពេញ)* | *អ្នកស្រី ខៀវ ចិន្តា* | *០៩២ ៥៨២ ៤៩៣* |
| *៣* | *សហគមន៍ដីធ្លីបឹងកក់ (ភ្នំពេញ)* | *លោក ច័ន្ទ ពុទ្ធិស័ក្តិ* | *០១២ ៩១០ ០២៣* |

[7] សម្រាប់ព័ត៌មានបន្ថែម សូមមើល ៖ កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក «ផលប៉ះពាល់សិទ្ធិមនុស្សដោយសារការបូមខ្សាច់នៅកម្ពុជា» ខែកញ្ញា ឆ្នាំ២០១៦ អាចរកបានតាមរយៈhttp://bit.ly/2epSPQC។

| | | | |
|---|---|---|---|
| ៤ | សហគមន៍បឹងត្របែក (ភ្នំពេញ) | លោក យុត ប៊ុនថាន | ០១២ ២១៤ ២៣៧ |
| ៥ | សហគមន៍បុរីកីឡា (ភ្នំពេញ) | អ្នកស្រី ឆាយ គឹមហន | ០១៧ ៥២២ ៣០៣ |
| ៦ | អនាគតយុវជនកម្ពុជាអាស៊ាន (CamAsean) | លោក ស្រ៊ុន ស្រ៊ន | ០៩៣ ៦០០ ២៣៤ |
| ៧ | សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា | អ្នកស្រី កេន ឆេងឡាង | ០១២ ៣៦៦ ៨៥៩ |
| ៨ | អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) | អ្នកស្រី យ៉ុន ម៉ាណោ | ០១២ ៣១៧ ៣៦៨ |
| ៩ | សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA) | លោក ឈឹម សាមុត | ០១២ ៩៦០ ៥១៥ |
| ១០ | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | លោក វណ្ណ សូផាត | ០១២ ៩៤១ ២០៦ |
| ១១ | គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ~សមាគមការពារ សិទ្ធិមនុស្សកម្ពុជា (CHRAC) | លោក អៀង ពេជ្រ | ០៩២ ៣៤៤ ៣៥៧ |
| ១២ | សមាគមអាដហុក ការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (ADHOC) | លោក អ៊ីន គា | ០១៥ ៨៣៦ ៨៣៨ |
| ១៣ | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ (LICAHDO) | លោក ថាវ គឹមសាន | ០១២ ៨០៧ ៧៦៣ |
| ១៤ | បណ្ដាញយុវជនកម្ពុជា (CYN) | លោក ទឹម ម៉ាឡៃ | ០១៧ ៩៩០ ៦៨៩ |
| ១៥ | សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA) | លោក ហឹម យន់ | ០១២ ៩៤៧ ០២២ |
| ១៦ | សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) | លោក ថេង សាវឿន | ០១២ ៧០៧ ៣៨១ |
| ១៧ | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) | លោក ញឹក សារិន | ០១២ ៨០០ ៥៦១ |
| ១៨ | បណ្ដាញកសាងសន្តិភាពសហគមន៍ (CPN) | លោក សេង សុខហេង | ០៩២ ៣២៤ ៦៦៨ |

| | | | |
|---|---|---|---|
| ១៩ | សហគមន៍ដក់ពរ (តាកែវ) | លោក សែម ប៊ុនលី | ០១៧ ៩៧៥ ៩៦៤ |
| ២០ | អង្គការសេមធម៌កម្ពុជា (EC) | លោក អៀង វុទ្ធី | ០១២ ៧៩១ ៧០០ |
| ២១ | សហគមន៍អតីតបណ្ដាញស្ត្រីបឹងកក់ (ភ្នំពេញ) | កញ្ញា អ៊ឹម ស្រីទូច | ០៧០ ៣០៦ ៦០៧ |
| ២២ | ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) | លោក សៀ ភារម្យ | ០១២ ៨៥២ ៣២៥ |
| ២៣ | បណ្ដាញព្រះសង្ឃឯកពជ្យដើម្បីយុត្តិធម៌សង្គម (IMNSI) | ព្រះតេជគុណ ប៊ុត ប៊ុនតេញ | ០១៦ ៦៦៦ ០៤២ |
| ២៤ | យុវជនជនជាតិដើមភាគតិច (ព្រះវិហារ) | លោក លូត សាំង | ០៩៧ ៤៥៦ ៦៤៦៦ |
| ២៥ | សមាគមឥន្ទ្រទេវី (IDA) | អ្នកស្រី ឌី វដ្ឋា | ០១២ ៨៩៧ ១៦១ |
| ២៦ | សមាគមយុវជនខ្មែរ (KYA) | អ្នកស្រី សិទ្ធិ ហុងអៀង | ០១៧ ៧៨៨ ៩៥៥ |
| ២៧ | សហគមន៍ព្រៃកស្រឡៅ (កោះកុង) | អ្នកស្រី នាក់ សុភាព | ០១៥ ៣០៤ ៨១៥ |
| ២៨ | សហគមន៍ជនជាតិដើមភាគតិចគួយ ភូមិព្រះមេរុ (ព្រះវិហារ) | អ្នកស្រី នួន មុំន | ០៩៧ ៧៧៣ ៧៥៤៩ |
| ២៩ | សហគមន៍ដីធ្លីភូមិ ១ (ក្រុងព្រះសីហនុ) | អ្នកស្រី ហង្ស ចិន្ដា | ០១២ ៦៨០ ៤៣៥ |
| ៣០ | សហគមន៍ដីធ្លី ភូមិព្រែកជីក (កោះកុង) | អ្នកស្រី ផាវ ញ៉ឹង | ០៧៧ ៥៣៧ ៦៥២ |
| ៣១ | សហគមន៍ដីធ្លីឃុំត្រែងត្រយឹង (កំពង់ស្ពឺ) | អ្នកស្រី វ៉ែម ផលចាន់លី | ០១០ ៦៦៦ ៩៧៦ |
| ៣២ | សហគមន៍ដីធ្លីភូមិក្រិញ (ប៉ៃលិន) | អ្នកស្រី អោម សំអុល | ០៩៦ ៨៤ ៧០ ៣៣៥ |
| ៣៣ | សហគមន៍ដីធ្លី ភូមិគ្រួស (បាត់ដំបង) | លោក លន់ គីឡា | ០៧៨ ៧២ ៦៧ ២៣ |
| ៣៤ | សហគមន៍ដីធ្លី ភូមិស្ពួន (សៀមរាប) | លោក វ៉ិច វី | ០៨៨ ២២៩ ៥២៩៧ |
| ៣៥ | សហគមន៍ដីធ្លីឡពាង (កំពង់ឆ្នាំង) | អ្នកស្រី អ៊ុំ សុភី | ០៧៨ ៧០៥ ៩៣៦ |

| | | | |
|---|---|---|---|
| ៣៦ | អង្គការមាតាធម្មជាតិ (MN) | លោក អាឡិច ហ្គុនសាឡេសដាវ៉ឹឌសុន | ០១៥ ៤២៦ ៤០៤ |
| ៣៧ | អិន វ៉ន អឹម (N1M) | អ្នកស្រី ហ្វេន ឡាំប្រ៊ីក | ០៩៦ ៥៣៧៤៧៤៣ |
| ៣៨ | អង្គការលើកស្ទួយប្រជាពលរដ្ឋ (P.I.O) | អ្នកស្រី នួន ភិមាន | ០១២ ៥៣០ ០៩៣ |
| ៣៩ | សហគមន៍ភ្នំបាត(កណ្តាល) | អ្នកស្រី ខៀវ ទ្បៃ | ០១១ ២៥ ០០ ៨១ |
| ៤០ | អង្គការពន្លកខ្មែរ | លោក អាង ជាតិឡោម | ០១២ ៥១៧ ៩៤៣ |
| ៤១ | សហគមន៍ផ្លូវរថភ្លើងទួលសង្កែ A (ភ្នំពេញ) | លោក ស៊ឹម វីរៈ | ០៦៩ ៩០៧ ៩៨៣ |
| ៤២ | សមាគមធាងត្នោត (STT) | លោក សឿង សារ៉ន | ០១២ ៨៣៦ ៥៣៣ |
| ៤៣ | សីលការ | អ្នកស្រី ធីតា ឃឹះ | ០១២ ៨៣៨ ៤៦៤ |
| ៤៤ | សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ | អ្នកស្រី ប្រាយ នីម | ០១៦ ៥៣៦ ៩០០ |
| ៤៥ | អង្គការតម្លាភាពកម្ពុជា (TIC) | លោក ព្រាប កុល | ០១២ ៨៧៧ ៨៣៣ |
| ៤៦ | យុវជនសន្តិភាព (YFP) | លោក ឡុង ខែត | ០១២ ៤០២ ៨៨០ |
| ៤៧ | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) | លោក ជាង សុខា | ០១២ ៣៦០ ៤៦៤ |